# ILO អំពាវនាវឲ្យមានកំណើនការងារច្រើនជាងមុន និងមានកិច្ចគាំពារសង្គមប្រសើរជាងមុននៅកម្ពុជា

សម្រាប់សេចក្តីប្រកាសព័ត៌មានជាបន្ទាន់៖ ថ្ងៃច័ន្ទ ទី៧ ខែវិច្ឆិកា ឆ្នាំ២០១១

Press Release សេចក្តីប្រកាសព័ត៌មាន

(ILO កម្ពុជា) ថ្ងៃនេះ អង្គការពលកម្មអន្តរជាតិបានសង្កត់ធ្ងន់ពីតម្រូវការនៃកំណើនការងារច្រើនជាងមុននៅកម្ពុជា ដែលក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ កំណើនការងារដែលបង្កើនផលិតភាពនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ក្នុងខណៈដែលសេដ្ឋកិច្ចប្រទេសជាតិកំពុងតែរីកចម្រើន។

លោកស្រី Sukti Dasgupta ដែលជាអ្នកជំនាញជាន់ខ្ពស់ខាងផ្នែកគោលនយោបាយការងារ និងទីផ្សារការងាររបស់ ILO មានប្រសាសន៍ថា ″ភាពប្រឈមគឺមិនគ្រាន់តែត្រូវបង្កើនចំនួនការងារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបង្កើនចំនួនការងារល្អៗផងដែរ″។ ‶ចំនួនប្រជាជនខ្មែរដែលមានអាយុធ្វើការងារ មានចំនួនកើនឡើងនៅក្នុងកម្រិតមួយយ៉ាងខ្ពស់បំផុតនៅក្នុងតំបន់ ប៉ុន្តែភាគច្រើនជាការងារដែលមិនផ្លូវការ ហើយមិនអាចជួយឲ្យប្រជាពលរដ្ឋជៀសផុតពីភាពក្រីក្របានទេ។ បញ្ហានេះត្រូវដោះស្រាយដោយបង្កើតការងារឲ្យបានច្រើនជាងមុនក្នុងផ្នែកតម្រូវការ និង ដោយបង្កើនគុណភាពការងារសម្រាប់ពលករ និងបង្កើតឡើងនូវស្ថាប័នដែលពាក់ព័ន្ធនានាខាងផ្នែកផ្គត់ផ្គង់″។

មុនវិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨ កម្ពុជាមានកំណើន GDP យ៉ាងខ្ពស់បំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក បន្ទាប់ពីប្រទេសចិន។ ទោះបីជាប្រទេសកម្ពុជាងើបពីវិបត្តិសេដ្ឋកិច្ចស្ទើរតែទាំងស្រុងក៏ដោយ ក៏ILO បានក្រើនរំលឹកថាការងារដែលបង្កើនផលិតភាពនៅកម្ពុជានៅមិនទាន់មានកំណើនលើស ពីរលាន នាក់នៃ ‶ជនក្រីក្រដែលធ្វើការ″ ក្នុងចំណោមកម្លាំងពលកម្មទាំងអស់ចំនួន ជាង ប្រាំពីរលាននាក់នៅឡើយទេ។ តម្រូវការដោះស្រាយនៃការកើនឡើងការងារយុវជនជាបញ្ហាត្រូវតែគិតគូរ។ ILO ក៏បានសង្កត់ធ្ងន់ពីការពង្រឹងនូវតម្រូវការកិច្ចគាំពារសង្គមនៅកម្ពុជាផងដែរ។ លោកស្រី Dasgupta មានប្រសាសន៍បន្ថែមទៀតថា ‶ភាពគ្មានការងារធ្វើនៅទីនេះ នៅមានកម្រិតទាបនៅឡើយ ត្រឹមចំនួនតែ ១.៦% ប៉ុណ្ណោះ ប៉ុន្តែបើគ្មានកិច្ចគាំពារសង្គមទេ ប្រជាជននឹងជ្រើសយកការងារណាដែលទំនងជាការងារងាយរងគ្រោះហើយមិនផ្តល់នូវជីវភាពល្អប្រសើរឡើយ″។ ‶កិច្ចគាំពារសង្គមនាំឲ្យមានការងារប្រសើរជាងមុន និងកំណើនការងារច្រើនជាងមុន ហើយសង្គមមានសមភាព និងផ្លែផ្កាជាងមុន″។

មតិចំណាប់អារម្មណ៍ជាច្រើនត្រូវបានលើកឡើងនាថ្ងៃនេះ នៅសណ្ឋាគារភ្នំពេញក្នុងសិក្ខាសាលាស្តីពី ‶ការលើកកម្ពស់កិច្ចគាំពារសង្គម និងការងារ″ ដែលសហការរៀបចំ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិ ដោយមានជំនួយមូលនិធិពីសហភាពអឺរ៉ុប (EU)។ នៅក្នុងសិក្ខាសាលានេះ ទាំងតំណាងរាជរដ្ឋាភិបាល និយោជក និងតំណាងសហជីព បានបង្ហាញពីមតិយោបល់ និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់វិសាលភាពកិច្ចគាំពារសង្គម ហើយអង្គការ ILO ក៏បានបង្ហាញពីលទ្ធផលការសិក្សាចំនួនពីរ ដែលអាចចូលរួមចំណែកក្នុងការអនុវត្ត យុទ្ធសាស្ត្រជាតិគាំពារសង្គម និងគោលនយោបាយមុខរបរដែលគ្រោងនឹងរៀបចំនាពេលខាងមុខ។

គណៈប្រតិភូ EU ប្រចាំនៅកម្ពុជាបានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាអំពីការអនុម័តនាពេលថ្មីៗនេះ លើយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។ ‶ប្រព័ន្ធកិច្ចគាំពារសង្គមទូលំទូលាយ ជាធាតុគន្លឹះសំខាន់នៃសិនិទ្ធពល និងស្ថេរភាពសង្គម។ ដូចនេះ EU សង្ឃឹមថាជំនួយរបស់ខ្លួនដែលផ្តល់តាមរយៈ ILO នឹងជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសេចក្តីសម្រេចនានា ដើម្បីសម្រេចបាននូវការប្តេជ្ញាចិត្តក្នុងការបង្កើនវិធានការកិច្ចគាំពារសង្គម ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះបំផុត។″

គម្រោង ILO-EU ស្តីពីការបង្កើនកិច្ចគាំពារសង្គមនិងមុខរបរ កំពុងតែសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូពាក់ព័ន្ធសំខាន់ៗនានាក្នុងការគាំទ្រយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលមានគោលដៅពង្រីកកិច្ចគាំពារសង្គមជាមូលដ្ឋានសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ រាជរដ្ឋាភិបាលកម្ពុជាក៏បានស្នើសុំជំនួយពី ILO ដើម្បីរៀបចំគោលនយោបាយជាតិមុខរបរ និងពង្រឹងកិច្ចគាំពារសង្គមក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ នាដំណាក់កាលបន្ទាប់ គម្រោងនេះមានគោលដៅសម្របសម្រួល និងជូនដំណឹងអំពីកិច្ចពិភាក្សានានាស្តីពីយុទ្ធសាស្ត្រគាំពារសង្គម និងយុទ្ធសាស្ត្រមុខរបរ ដែលនឹងបញ្ចប់នូវការសិក្សាទាំងឡាយ ដែលរួមបញ្ចូលទាំងការអង្កេត និងអនុសាសន៍ដែលទទួលបានពីសិក្ខាសាលា។ នៅដើមឆ្នាំ ២០១២ នេះ របាយការណ៍ទី ៣ នឹងត្រូវរៀបចំឡើងសម្រាប់កម្ពុជា ស្តីពីការមានគោលនយោបាយសង្គម និងមុខរបរនៅកម្ពុជា ឬនឹងត្រូវរៀបផែនការសម្រាប់កម្ពុជា ដើម្បីជួយពង្រឹងគ្នាទៅវិញទៅមក។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈ
Maeve Galvin
ការិយាល័យទំនាក់ទំនង និងតស៊ូមតិ
ការិយាល័យគម្រោងរួមគ្នារបស់ ILO ភ្នំពេញ, កម្ពុជា
E-mail: galvin@ilo.org Tel: (855) 23 220 817 / www.ilo.org/asia



ឯកសារនេះសម្រាប់ជាព័ត៌មានប៉ុណ្ណោះ។ ឯកសារនេះមិនមែនជាកំណត់ត្រាផ្លូវការណាមួយឡើយ